**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
លេខ ១៩៧.១.(វក

# ប្រ កា ស
## ស្តីពីការដាក់តាំង ផ្ទាំងយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្ម ផ្ទាំងសញ្ញា

---------

## រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដាឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម /០១៩៦/០២ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យ លេខ ៦២ អ.ន.ក្រ /ប.ក ចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញសេចក្តីជូនដំណឹងលេខ ១៣៥ សជណ.សរ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០២ ស្តីពីលទ្ធផលសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី ១១ ខែមករា ឆ្នាំ២០០២ និងស្មារតីអង្គប្រជុំអន្តរក្រសួង នាទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០២

## ស ម្រេ ច

ប្រ កា រ ១ :

- ផ្ទាំងយីហោ គឺគ្រឿងបង្ហាញ និងសំគាល់នាម របស់អាជីវករ គ្រឹះស្ថាននានា ដែលធ្វើការផលិត ធ្វើសេវាកម្ម ឬធ្វើពាណិជ្ជកម្ម ។

- ផ្ទាំងផ្សាយពាណិជ្ជកម្ម គឺជាគ្រឿង បង្ហាញ និង ផ្សព្វផ្សាយ យីហោ ឬ មុខទំនិញ សំដៅទាក់ទាញ អតិថិជន ក្នុងគោលដៅធ្វើអាជីវកម្ម ។
- ផ្ទាំងសញ្ញា គឺជាគ្រឿង សំគាល់ និង បង្ហាញអំពី ព្រឹត្តិការណ៍ ពត៌មាន សកម្មភាព និមិត្តរូប ពេលវេលា ឈ្មោះ ជូនសាធារណជន សំរាប់ ចំណាំ ចងចាំ និង អនុវត្ត ។

ប្រការ ២ :

អំពីរូបភាព ការដាក់តាំងផ្សព្វផ្សាយ និង ការគ្រប់គ្រងត្រួតពិនិត្យ ផ្ទាំងយីហោ ផ្ទាំងផ្សាយ-ពាណិជ្ជកម្ម ផ្ទាំងសញ្ញា ត្រូវសរសេរឱ្យបានត្រឹមត្រូវ តាមពាក្យពេចន៍ និងអក្ខរាវិរុទ្ធជា **អក្សរខ្មែរ** ដោយអនុវត្តតាមវចនានុក្រមរបស់សម្តេចព្រះមហាសុមេធាធិបតីជោតញ្ញាណោ **"ជួន ណាត"** បោះពុម្ពនាឆ្នាំ ១៩៦៧ - ១៩៦៨ ជាមូលដ្ឋាន។

អក្សរខ្មែរត្រូវសរសេរអោយបានធំជាងអក្សរបរទេស ហើយដាក់នៅជួរខាងលើគេបំផុត ។

ប្រការ ៣:

អក្សរបរទេសអាចសរសេរនៅពីខាងក្រោមហើយមានទំហំពាក់កណ្តាលនៃ **អក្សរខ្មែរ** ។ អក្សរបរទេសត្រូវសរសេរអោយបានត្រឹមត្រូវតាមពាក្យពេចន៍ អក្ខរាវិរុទ្ធជាអក្សរបរទេសនិមួយៗ ដើម្បីលើកតម្កើងកិត្យានុភាពជាតិ ។

ប្រការ ៤:

ម្ចាស់ដាក់តាំង និង ផ្សព្វផ្សាយ ផ្ទាំងយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្ម ផ្ទាំងសញ្ញា ត្រូវកែលំអឱ្យបានសមស្របតាមប្រកាសនេះ ។

ប្រការ ៥:

រាជធានីភ្នំពេញ ខេត្តសៀមរាប និងក្រុងព្រះសីហនុ ត្រូវអនុវត្តជាបន្ទាន់នូវកិច្ចការនេះឱ្យបានចប់ជាស្ថាពរនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០២ ។

ប្រការ ៦:

ខេត្ត-ក្រុង ទូទាំងព្រះរាជាណាចក្រកម្ពុជាដែលពុំមានចែងក្នុងប្រការ៥ ត្រូវអនុវត្តកិច្ចការនេះឱ្យបានចប់ជាស្ថាពរនៅថ្ងៃ ទី៣១ ខែធ្នូ ឆ្នាំ២០០២។

ប្រការ ៧:

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្ត - ក្រុង ទទួលរូបភាព និង ខ្លឹមសារ ត្រូវសហការជាមួយអាជ្ញាធរដែនដី និងអង្គភាព ជំនាញពាក់ព័ន្ធ ដើម្បីអនុវត្តតាមប្រកាសនេះឱ្យទទួលបានលទ្ធផលល្អ។

ប្រការ ៨:

គ្រប់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្ត-ក្រុង ត្រូវធ្វើរបាយការណ៍ជាទៀងរាល់ខែអំពីលទ្ធផលនៃការអនុវត្តន៍តាមប្រកាសនេះ ផ្ញើមកក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដើម្បីបូកសរុបរាយការណ៍ជូនរាជរដ្ឋាភិបាល ។

ប្រការ ៩:

ខុទ្ទកាល័យរដ្ឋមន្ត្រី អធិការដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ សាកលវិទ្យាល័យភូមិន្ទ វិចិត្រសិល្បៈ គ្រប់នាយកដ្ឋានក្រោមឱវាទ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ និងគ្រប់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង មានកាតព្វកិច្ចអនុវត្តតាមប្រកាសនេះ អោយមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៧ខែកក្កដា ឆ្នាំ២០០២

រដ្ឋមន្ត្រី

នរោត្តម - បុប្ផាទេវី

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង - ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ